**THE SCHOOL DISTRICT OF PHILADELPHIA**

[school name]
[address]
Philadelphia, PA 19

**"Please fill out the English portion of the form you require, the target language portion will be filled out automatically"**

_____________________
**Principal**

**Phone: 215-**
**Fax: 215-**

December 7, 2012

Dear Parents and Caregivers:

Due to inclement weather or other emergencies, it may be necessary to **cancel school for the day**, **dismiss school early** or have a **"delayed opening."** If this should occur, parents and caregivers are asked to tune into the local news, visit The School District of Philadelphia's website at www.philasd.org, or call the District's Parent hotline at 215-400-INFO (4636).

**Delayed School Opening**

In the event of a delayed opening, all schools and early childhood programs will open at 10:00 AM. Dismissal time will remain the same. Yellow bus transportation will run on a 90 minute delayed schedule. The transportation schedule for a delayed opening is posted on the back. All school trips that are scheduled will be canceled. Breakfast, lunch, after school programming and athletics will not be affected and will function as normal.

**Early Dismissal**

If the decision is made to dismiss schools early, schools will notify parents via the District's School Messenger service, local news outlets and the District's website. Where applicable food service will be made available to students and transportation services will be adjusted to meet the needs of the early dismissal.

**Full Day School Cancelation/Closing**

If schools are to close for a full day, every effort will be made to notify families the night before the closure. Students are not to report to school on the day indicated and notification will be posted on the District's website and provided to local news outlets. Families are encouraged to visit the District's website regularly for updated information

We strongly encourage you to make arrangements for your child's supervision when schools are closed or delayed and to review these arrangements with your child periodically.

Sincerely,

_____________________
Principal

# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា

[school name]
[address]
Philadelphia, PA 19


____________________ ទូរស័ព្ទ៖ 215-

**នាយកសាលា** **ទូរសារ៖ 215-**


ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១២

ជូនចំពោះមាតាបិតា និង អាណាព្យាបាល៖

ដោយសារធាតុអាកាសមិនល្អ ឬដោយសារមានបញ្ហាបន្ទាន់ផ្សេងៗទៀត វាជាការចាំបាច់ដែលយើងត្រូវ **បិទសាលាមួយថ្ងៃ ឲ្យសិស្សចេញមុនម៉ោង** ឬ «**ពន្យាម៉ោងបើកសាលា**»។ ប្រសិនបើមានបញ្ហានេះកើតឡើង សូមឲ្យមាតាបិតា និងអាណាព្យាបាល តាមដានស្ដាប់ព័ត៌មានប្រចាំតំបន់ មើលក្នុងវ៉ិបសៃរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា www.philasd.org ឬ ទូរស័ព្ទមកខ្សែទូរស័ព្ទសំខាន់សម្រាប់មាតាបិតា លេខ (២១៥) ៤០០-INFO (៤៦៣៦)។

## <u>ពន្យាម៉ោងបើកសាលា</u>

នៅពេលមានការពន្យាម៉ោងបើកសាលា គ្រប់សាលា និងកម្មវិធីសម្រាប់កុមារមុនថ្នាក់មត្តេយ្យទាំងអស់ នឹងបើកនៅម៉ោង ១០:០០ព្រឹក។ ម៉ោងបិទសាលានឹងរក្សានៅដដែល។ <u>រថយន្តដឹកសិស្សពណ៌លឿងនឹងពន្យាពេល៩០នាទី។ តារាងពេលវេលាសម្រាប់យានជំនិះនៅពេលពន្យាម៉ោងបើកសាលា មាននៅទំព័រខាងក្រោយ។</u> ដំណើរកំសាន្តរបស់សាលាទាំងអស់ នឹងត្រូវផ្អាក។ នឹងគ្មានការប៉ះពាល់ដល់ អាហារពេលព្រឹក អាហារថ្ងៃត្រង់ កម្មវិធីក្រោយម៉ោងសិក្សា និងការលេងកីឡាទេ គឺត្រូវដំណើរការជាធម្មតា។

## <u>ឲ្យសិស្សចេញមុនម៉ោង</u>

បើសិនជាគេសម្រេចចិត្តឲ្យសិស្សចេញមុនម៉ោង សាលានឹងជម្រាបទៅមាតាបិតាតាមរយៈ សេវាផ្ដល់ព័ត៌មានរបស់ក្រសួង ការផ្សាយព័ត៌មាននៅតាមតំបន់ និងវ៉ិបសៃរបស់ក្រសួង។ សេវាម្ហូបអាហារនឹងមានសម្រាប់សិស្ស ហើយសេវាយានជំនិះត្រូវបានគេកែតម្រូវឲ្យត្រូវតាមសេចក្ដីត្រូវការនៃការឲ្យចេញមុនម៉ោង។

## <u>បិទសាលាមួយថ្ងៃ</u>

បើសិនជាត្រូវបិទសាលាមួយថ្ងៃ នឹងមានការខំប្រឹងប្រែងគ្រប់បែបយ៉ាង ដើម្បីជម្រាបទៅក្រុមគ្រួសារនូវយប់មុនថ្ងៃបិទសាលា។ សិស្សានុសិស្សមិនត្រូវទៅសាលានៅថ្ងៃដែលគេបានបញ្ជាក់ប្រាប់ ហើយការផ្ដល់ព័ត៌មាន នឹងដាក់នៅក្នុងវ៉ិបសៃរបស់ក្រសួង និងផ្ដល់ទៅឲ្យក្រុមផ្សាយព័ត៌មាននៅក្នុងតំបន់។ សូមឲ្យមាតាបិតាឧស្សាហ៍មើលវ៉ិបសៃរបស់ក្រសួង ដើម្បីជ្រាបពីព័ត៌មានថ្មីៗ។

យើងខ្ញុំសូមឲ្យលោកអ្នករៀបចំគម្រោងការជាចាំបាច់ សម្រាប់ការមើលថែកូនរបស់លោកអ្នក នៅពេលដែលសាលាត្រូវបិទ ឬត្រូវពន្យាម៉ោងបើកសាលា ហើយពិនិត្យមើលគម្រោងការទាំងនេះឡើងវិញជារឿយៗ ជាមួយកូនរបស់លោកអ្នក។

ដោយសេចក្ដីស្មោះស្ម័គ្រ

____________________

នាយកសាលា

ដើម្បីជ្រាបពីឯកសារដែលបានបកប្រែ និងព័ត៌មានបន្ថែមជាភាសាខ្មែរ សូមមើលក្នុងវ៉ិបសៃ៖ www.philasd.org/language/khmer

# តារាងម៉ោងសម្រាប់រថយន្តដឹកសិស្ស នៅពេលពន្យាម៉ោងបើកសាលា

| **ម៉ោងដឹកសិស្ស តាមពេលធម្មតា (ពេលព្រឹក)** | **ម៉ោងដឹកសិស្ស នៅពេលពន្យាម៉ោងបើកសាលា (ពេលព្រឹក)** |
|---|---|
| ៧:១០ | ៨:៤០ |
| ៧:១៥ | ៨:៤៥ |
| ៧:២០ | ៨:៥០ |
| ៧:២៥ | ៨:៥៥ |
| ៧:៣០ | ៩:០០ |
| ៧:៣៥ | ៩:០៥ |
| ៧:៤០ | ៩:១០ |
| ៧:៤៥ | ៩:១៥ |
| ៧:៥០ | ៩:២០ |
| ៧:៥៥ | ៩:២៥ |
| ៨:០០ | ៩:៣០ |
| ៨:០៥ | ៩:៣៥ |
| ៨:១០ | ៩:៤០ |
| ៨:១៥ | ៩:៤៥ |
| ៨:២០ | ៩:៥០ |
| ៨:២៥ | ៩:៥៥ |
| ៨:៣០ | ១០:០០ |
| ៨:៣៥ | ១០:១០ |
| ៨:៤០ | ១០:១៥ |
| ៨:៤៥ | ១០:២០ |
| ៨:៥០ | ១០:២៥ |
| ៨:៥៥ | ១០:៣០ |
| ៩:០០ | ១០:៣៥ |

*** គ្មានការប៉ះពាល់ដល់ ម៉ោងចេញពីរៀន និងការដឹងក្មេងទៅផ្ទះវិញទេ ម៉ោងពេលនឹងរក្សានៅដដែល ***

ដើម្បីជ្រាបពីឯកសារដែលបានបកប្រែ និងព័ត៌មានបន្ថែមជាភាសាខ្មែរ សូមមើលក្នុងវ៉ិបសៃ៖ www.philasd.org/language/khmer